**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ..៤៦២.....សហវ..[illegible]

# ប្រកាសអន្តរក្រសួង
## ស្ដីពី
## ការបែងចែកចំណូលពីសេវាសាធារណៈលើការជូនដំណឹង ការចេញវិញ្ញាបនបត្រជាមុន និងការចុះបញ្ជីការរួមបញ្ចូលគ្នានៃធុរកិច្ច និងការពិន័យចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្ដីពីសុវត្ថិភាពម្ហូបអាហារ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២២/០០៦ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣ ស្តីពីលក្ខខណ្ឌ និងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច
- បានឃើញសេចក្តីសម្រេចលេខ២៥ សសរ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ របស់រាជរដ្ឋាភិបាល ស្តីពីការបង់ភាគទានរបស់ក្រសួង ស្ថាប័ន ចូលក្នុងមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសអន្តរក្រសួងលេខ...៤១១... សហវ.ប្រក.អទច ចុះថ្ងៃទី...១៧... ខែ...កក្កដា... ឆ្នាំ២០២៣ ស្តីពីការផ្តល់សេវាសាធារណៈលើការជូនដំណឹង ការចេញវិញ្ញាបនបត្រជាមុន និងការចុះបញ្ជីការរួមបញ្ចូលគ្នានៃធុរកិច្ច
- បានឃើញប្រកាសអន្តរក្រសួងលេខ...៤១២... សហវ.ប្រក.អទច ចុះថ្ងៃទី...១៧... ខែ...កក្កដា... ឆ្នាំ២០២៣ ស្តីពីការពិន័យអន្តរការណ៍ចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

ចំណូលពីការផ្តល់សេវាសាធារណៈលើការជូនដំណឹង ការចេញវិញ្ញាបនបត្រជាមុន និងការចុះបញ្ជីការរួមបញ្ចូលគ្នានៃធុរកិច្ច និងការពិន័យចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ ដែលប្រមូលបានដោយក្រសួងពាណិជ្ជកម្ម ត្រូវបានបែងចែកដូចខាងក្រោម ÷

ក- ចំណូលពីការផ្តល់សេវាសាធារណៈលើការជូនដំណឹង ការចេញវិញ្ញាបនបត្រជាមុន និងការចុះបញ្ជីការរួមបញ្ចូលគ្នានៃធុរកិច្ច

១- បង់ចូលថវិកាជាតិ ចំនួន ៤១% នៃចំណូលប្រមូលបាន

២- ប្រាក់រង្វាន់របស់ក្រសួងពាណិជ្ជកម្ម ចំនួន ៥៩% នៃចំណូលប្រមូលបាន
ត្រូវបានកំណត់ដូចតទៅ ÷

- បង់ភាគទានចូលមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចំនួន ១០% នៃ ៥៨%
- ប្រើប្រាស់នៅក្រសួងពាណិជ្ជកម្ម ចំនួន ៩០% នៃ ៥៨%

៣- ប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំនួន ១% នៃចំណូលប្រមូលបាន ។

ខ- ចំណូលពីការពិន័យអន្តរការណ៍ចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ

១- បង់ចូលថវិកាជាតិ ចំនួន ៤១% នៃចំណូលប្រមូលបាន

២- ប្រាក់រង្វាន់របស់ក្រសួងពាណិជ្ជកម្ម ចំនួន ៥៨% នៃចំណូលប្រមូលបាន

ត្រូវបានកំណត់ដូចតទៅ ÷

- បង់ភាគទានចូលមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចំនួន ១០% នៃ ៥៨%
- ប្រើប្រាស់នៅក្រសួងពាណិជ្ជកម្ម ចំនួន ៩០% នៃ ៥៨%

៣- ប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំនួន ១% នៃចំណូលប្រមូលបាន ។

គ- ចំណូលពីការផ្តន្ទាទោសពិន័យជាប្រាក់ចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ

១- បង់ចូលថវិកាជាតិ ចំនួន ១៧% នៃចំណូលប្រមូលបាន

២- ប្រាក់រង្វាន់របស់ក្រសួងពាណិជ្ជកម្ម ចំនួន ៥៨% នៃចំណូលប្រមូលបាន

ត្រូវបានកំណត់ដូចតទៅ ÷

- បង់ភាគទានចូលមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចំនួន ១០% នៃ ៥៨%
- ប្រើប្រាស់នៅក្រសួងពាណិជ្ជកម្ម ចំនួន ៩០% នៃ ៥៨%

៣- ប្រាក់រង្វាន់សរុបរបស់សាលាជម្រះក្តីពាក់ព័ន្ធ ចំនួន ២៤% នៃចំណូលប្រមូលបាន

៤- ប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំនួន ១% នៃចំណូលប្រមូលបាន ។

**ប្រការ២ ._**

អនុញ្ញាតឱ្យក្រសួងពាណិជ្ជកម្ម បុរេប្រទានប្រាក់រង្វាន់សរុបដែលបានកំណត់ក្នុងប្រការ១ នៃប្រកាសអន្តរក្រសួងនេះ ដោយដកយកពីចំណូលប្រមូលបាន និងបើកផ្តល់ចំណែកប្រាក់រង្វាន់ជូនដល់អង្គភាពគោលដៅនីមួយៗ។

**ប្រការ៣ ._**

ជារៀងរាល់ខែ ក្រសួងពាណិជ្ជកម្ម ត្រូវធ្វើការទូទាត់ប្រាក់រង្វាន់ដែលបានបុរេប្រទានប្រចាំខែ ដោយអនុវត្តតាមនីតិវិធីដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៤ ._**

ការផ្តល់ប្រាក់រង្វាន់ ដែលមានចែងក្នុងប្រកាសអន្តរក្រសួងនេះ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់ការចំណាយឧបត្ថម្ភជូនមន្ត្រីរាជការដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត និងប្រើប្រាស់សម្រាប់ការចំណាយពង្រឹងយន្តការប្រមូលចំណូល។

ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងពាណិជ្ជកម្ម ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ១៤ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន-សូរស័ក្តិ**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ